00649951

E9/14/1/2

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | ខ្មែរ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 03 / 2011
ម៉ោង (Time/Heure): 15:59
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ / Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សំណើសុំពន្យារពេលឆ្លើយតបចំពោះការជំទាស់របស់សហព្រះរាជអាជ្ញា នៅនឹងសាក្សី និងអ្នកជំនាញដែលបានស្នើឡើងដោយភាគីដទៃ

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ជនជាប់ចោទ និង មេធាវីការពារក្តី**
**ជនជាប់ចោទ:**
នួន ជា
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe

អៀង សារី
លោក អាង ឧត្តម
លោក Michael G.KARNAVAS

ខៀវ សំផន
លោក ស សូវាន
លោក Jacques VERGÈS

លោក Phillipe GRECIANO

**អៀង ធីរិទ្ធ**
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC

# សេចក្តីផ្តើម

១. អនុលោមតាម *"ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ"* របស់អង្គជំនុំជម្រះសាលាដំបូង ("ដីកាបង្គាប់")[1] សហព្រះរាជអាជ្ញា នឹងដាក់ជូនពីការជំទាស់របស់ខ្លួនទៅនឹងការកោះហៅសាក្សី និងអ្នកជំនាញមួយចំនួនដែលបានស្នើឡើងដោយភាគីដទៃ។

២. ជាសរុប គូភាគី ដោយរួមទាំងសហព្រះរាជអាជ្ញាផង បានស្នើសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ជាសរុបចំនួន ១០៩៥ នាក់។ ដែលក្នុងនោះ សហព្រះរាជអាជ្ញាបានស្នើសាក្សី និងអ្នកជំនាញសរុបចំនួន ២៩៥នាក់។ នួន ជា បានស្នើសាក្សី និងអ្នកជំនាញសរុប ចំនួន ៥២៧នាក់ (រួមទាំងសាក្សី៣១នាក់នៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា)[2] អ្នកជំនាញ១៣នាក់ និងដើមបណ្តឹងរដ្ឋប្បវេណី៥នាក់[3]។ ខៀវ សំផន បានស្នើសាក្សី៣៥នាក់ (បន្ថែមពីលើសាក្សី២៦នាក់នៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា) និងអ្នកជំនាញ៣២នាក់[4]។ អៀង ធីរិទ្ធ បានស្នើសាក្សី និងអ្នកជំនាញសរុបចំនួន ៩នាក់[5]។ អៀង សារី បានស្នើអ្នកជំនាញ ៥នាក់[6] ហើយភាគីដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសាក្សី១៦នាក់ អ្នកជំនាញ១៥នាក់ និងដើមបណ្តឹងរដ្ឋប្បវេណី១៤០នាក់[7]។

៣. សហព្រះរាជអាជ្ញា ជូនដំណឹងអំពីគោលបំណងនៃការជំទាស់ទៅនឹងការស្តាប់សវនាការលើសាក្សី និងអ្នកជំនាញជាក់លាក់មួយចំនួនដែលបានស្នើឡើងដោយ នួន ជា, ខៀវ សំផន, អៀង ធីរិទ្ធ និង អៀង សារី និងភាគីដើមបណ្តឹងរដ្ឋប្បវេណី។

---

[1] **ឯកសារលេខ** E9, "ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ" ១៧ មករា ២០១១, ERN 00635754-00635759 ។ **ឯកសារលេខ** E9/4, "បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជអាជ្ញា រួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១, ២, ៣, ៣ក, ៤, និង ៥", ២៨ មករា ២០១១, ERN 00640669-00640844 ។

[2] **ឯកសារលេខ** E9/4/4.4, "ឧបសម្ព័ន្ធ ក: បញ្ជីឈ្មោះសាក្សីដែលស្នើឡើង (ដែលមិនត្រូវការវិធានការការពារ), ក្រុមមេធាវីការពារក្តី នួន ជា", ១៥ កុម្ភៈ ២០១១, ERN 00645893-00646073 ។

[3] **ឯកសារលេខ** E9/4/4, "បញ្ជីឈ្មោះសាក្សីដែលស្នើឡើង និងដើមបណ្តឹងរដ្ឋប្បវេណី", ១៥ កុម្ភៈ ២០១១, ERN 00644417-00644444 ។

[4] **ឯកសារលេខ** E9/4/6, 'Listes de Témoins et Experts Proposés', ២១ កុម្ភៈ ២០១១, ERN 00646238-00649194 ។

[5] **ឯកសារលេខ** E9/4/5, "បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ អៀង ធីរិទ្ធ", ១៥ កុម្ភៈ ២០១១, ERN 00644447-00644453 ។

[6] **ឯកសារលេខ** E9/4/2, "បញ្ជីឈ្មោះអ្នកជំនាញដែលស្នើឡើង របស់ អៀង សារី និងការជូនដំណឹងទាក់ទិននឹងបញ្ជីឈ្មោះសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់", ១៤ កុម្ភៈ ២០១១, ERN 00644216-00644222 ។

[7] **ឯកសារលេខ** E9/4/3, "បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន៨០ របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១, ២ក, ២ខ, ៣ក, ៣ខ និង ៤", ១៥ កុម្ភៈ ២០១១, ERN 00645265-00645352 ។

៤. សហព្រះរាជអាជ្ញា សូមជម្រាបជូនថា បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី ដែលគូភាគីបានដាក់មក គឺភាគច្រើនសុទ្ធតែជាភាសាបរទេស ដែលធ្វើឱ្យមានផលវិបាកជាយថាហេតុ សម្រាប់ សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិក្នុងការពិភាក្សាគ្នាថា គួរធ្វើការជំទាស់ ឬមិនជំទាស់ទៅលើសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី ណាខ្លះនោះ។

៥. លើសពីនេះទៀត ការិយាល័យសហព្រះរាជអាជ្ញា បានធ្វើពង្រាងជាភាសាអង់គ្លេស អំពីឧបសម្ព័ន្ធនៃបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវជំទាស់ទៅនឹងការស្នើឡើងដោយគូភាគីផ្សេងៗទៀត។ ដោយសារលក្ខណៈស្មុគ្រស្មាញ និងទំហំការងារធំធេងនោះ ឧបសម្ព័ន្ធនៃបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី ជាភាសាអង់គ្លេសនោះ ទើបតែធ្វើរួចរាល់នៅវេលាម៉ោង បីរសៀល។

៦. ដោយសារតែពេលវេលាដូចបញ្ជាក់ជូនខាងលើនេះហើយ ទើបសហព្រះរាជអាជ្ញាជាតិ មិនអាចពិនិត្យលើបញ្ជីឈ្មោះដែលមានក្នុងឧបសម្ព័ន្ធជាភាសាអង់គ្លេសនោះឱ្យបានត្រឹមត្រូវ និងសព្វជ្រុងជ្រោយបានឡើយ។

៧. ដើម្បីមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការពិនិត្យស្វែងយល់ និងពិចារណាឱ្យបានត្រឹមត្រូវ និងដើម្បីជួយដល់អង្គជំនុំជម្រះនៅក្នុងការវាយតម្លៃលើការជំទាស់នោះ សហព្រះរាជអាជ្ញាជាតិ សូមការអនុញ្ញាតិពីអង្គជំនុំជម្រះសាលាដំបូង ដើម្បីពន្យារពេលក្នុងការដាក់ការឆ្លើយតបទៅនឹងការជំទាស់បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីឱ្យសហព្រះរាជអាជ្ញាជាតិ មានលទ្ធភាពក្នុងការសិក្សាទៅលើបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី ដែលគូភាគីបានដាក់មកនេះឱ្យបានច្បាស់លាស់ជាមុនសិន មុននឹងអាចដាក់ជូនការជំទាស់របស់ខ្លួនទៅលើបញ្ជីឈ្មោះទាំងនោះ។

## សំណើ

៨. អាស្រ័យដូចបានរៀបរាប់ខាងលើ សហព្រះរាជអាជ្ញាជាតិ សូមការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង ពន្យារពេលក្នុងការដាក់ឯកសារឆ្លើយតបនេះរហូតដល់ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ២០១១៕

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១១

សហព្រះរាជអាជ្ញាជាតិ

ជា លាង